**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.១៧...០១៩៧...១១៧.ប្រ.ក....

# ប្រកាស
## ស្តីពី
## ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រី-បុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

* * * * * * *

## ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងកាប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៥៦ អនក្រ.តត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមស្មារតីរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.~**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់សីលធម៌វិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ គុណភាព និងប្រសិទ្ធភាពការងាររបស់មន្ត្រី-បុគ្គលិកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាតទៅនេះហៅថា "ស.ហ.ក" ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រី-បុគ្គលិក ស.ហ.ក ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រី-បុគ្គលិកដែលបាននិងកំពុងបម្រើការងារជូន ស.ហ.ក ។

## ជំពូកទី២
## ករណីយកិច្ច និងការទទួលខុសត្រូវទូទៅ

**ប្រការ ៤.-**

មន្ត្រី-បុគ្គលិក ដែលបាននិងកំពុងបំពេញមុខងារនិងភារកិច្ចជូន ស.ហ.ក. ត្រូវមានករណីយកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

១- គោរពជីវិត រាងកាយ ចិត្ត សេចក្តីថ្លៃថ្នូររបស់មនុស្ស គោរពវិន័យការងារ បទបញ្ជាផ្ទៃក្នុង និងត្រូវប្រកាន់ខ្ជាប់នូវសីលធម៌វិជ្ជាជីវៈ

២- ស្មោះត្រង់ និងមានភាពសុចរិតឥតល្អៀងចំពោះ ស.ហ.ក

៣- មានស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខងារនិងភារកិច្ចដែល ស.ហ.ក ប្រគល់ជូន និងត្រូវអនុវត្តការងារនោះឲ្យមានប្រសិទ្ធភាពជូនអង្គភាព និងសង្គមជាតិ

៤- មានកាតព្វកិច្ចគោរពគោលការណ៍រក្សាការសម្ងាត់វិជ្ជាជីវៈនៃព័ត៌មាន ក្នុងក្របខ័ណ្ឌការងាររបស់ខ្លួន ។ កាតព្វកិច្ចនេះនៅតែត្រូវបន្តអនុវត្ត ទោះបីមន្ត្រី-បុគ្គលិកនោះបានឈប់បម្រើការងារពី ស.ហ.ក ហើយក៏ដោយ ស្របតាមមាត្រា២៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

៥- ខិតខំអភិវឌ្ឍខ្លួនឯង តាមរយៈការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល និងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឲ្យមាន គុណភាព និងប្រសិទ្ធភាពខ្ពស់ ។

## ជំពូកទី៣
## ទំនាក់ទំនងផ្ទៃក្នុង និងភាគីពាក់ព័ន្ធ

**ប្រការ ៥.-**

មន្ត្រី-បុគ្គលិកត្រូវគោរពនិងប្រតិបត្តិតាមឋានានុក្រមរដ្ឋបាល មានទំនាក់ទំនងនិងសាមគ្គីផ្ទៃក្នុងល្អ ដើម្បីកសាងវប្បធម៌ការងារគំរូ និងសេចក្តីថ្លៃថ្នូរ ។

**ប្រការ ៦.-**

មន្ត្រី-បុគ្គលិកត្រូវមានទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ ដោយប្រកាន់ខ្ជាប់នូវសីលធម៌ សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាទន់ភ្លន់ ស្លូតបូត សុភាពរាបសា និងរួសរាយរាក់ទាក់ ក្នុងពេលបំពេញមុខងារនិងភារកិច្ចជូន ស.ហ.ក ។

## ជំពូកទី ៤
## ការហាមឃាត់ចំពោះមន្ត្រី-បុគ្គលិក ស.ហ.ក

**ប្រការ ៧.-**

មន្ត្រី-បុគ្គលិកមិនត្រូវធ្វើឲ្យបាត់បង់មនសិការរបស់ខ្លួនក្នុងការបំពេញមុខងារនិងភារកិច្ច ដែលបណ្តាលឲ្យប៉ះពាល់ដល់គុណភាព ប្រសិទ្ធភាពការងារ និងកេរ្តិ៍ឈ្មោះរបស់ ស.ហ.ក និងផលប្រយោជន៍សង្គមជាតិ ។

**ប្រការ ៨.-**

មន្ត្រី-បុគ្គលិក ស.ហ.ក ៖

- មិនត្រូវបរិហាកេរ្តិ៍ ប្រមាថ ឬមើលងាយថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិក ឬដៃគូពាក់ព័ន្ធ
- មិនត្រូវកេងចំណេញពី ស.ហ.ក សម្រាប់ជាផលប្រយោជន៍ផ្ទាល់ខ្លួន ក្រុមនិង/ឬ សម្រាប់ស្ថាប័ន និងអង្គភាពផ្សេង ទោះបីក្រោមរូបភាពណាក៏ដោយ
- មិនត្រូវផ្សព្វផ្សាយអំពីការវិនិច្ឆ័យរដ្ឋបាលចំពោះមន្ត្រី-បុគ្គលិកណាម្នាក់ លិខិតស្នាម រដ្ឋបាល និងព័ត៌មានផ្ទៃក្នុងរបស់ ស.ហ.ក តាមប្រព័ន្ធផ្សព្វផ្សាយនានាដោយគ្មានការអនុញ្ញាតឡើយ
- ត្រូវចៀសវាងរាល់ការទទួលយកអំណោយ លាភសក្ការៈ ឬ/និងផលប្រយោជន៍ផ្សេងៗ ដែលធ្វើឲ្យប៉ះពាល់ដល់សកម្មភាព គុណភាព និងប្រសិទ្ធភាពការងារ ព្រមទាំងកេរ្តិ៍ឈ្មោះរបស់ ស.ហ.ក
- មិនត្រូវលេងល្បែងស៊ីសង និងកេងប្រវ័ញ្ច ដែលអាចប៉ះពាល់ដល់កិត្យានុភាព និងសេចក្តីថ្លៃថ្នូររបស់ ស.ហ.ក
- មិនត្រូវប្រព្រឹត្ត ឬបំពេញការងារណាដែលផ្ទុយពី ច្បាប់ ទំនៀមទម្លាប់ វប្បធម៌ និងប្រពៃណីជាតិឡើយ
- ត្រូវចៀសវាងរាល់ការរើសអើងជាតិសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា កាយសម្បទា អាយុ ភេទ និងទស្សនៈនយោបាយផ្សេងៗ ។

**ប្រការ ៩.-**

មន្ត្រី-បុគ្គលិកមិនត្រូវបានអនុញ្ញាតឲ្យទៅបម្រើការងារក្នុងមុខតំណែង ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់សហព័ទ្ធឡើយ ។

**ប្រការ ១០.-**

មន្ត្រី-បុគ្គលិកមិនត្រូវបានអនុញ្ញាតឲ្យទៅបម្រើការងារក្នុងមុខតំណែងណាមួយរបស់បុគ្គលរាយការណ៍ ដែលខ្លួនធ្លាប់ពាក់ព័ន្ធ ឬនាំឲ្យមានទំនាស់ផលប្រយោជន៍មុនពេលលាឈប់ពីការងារ ឬចូលនិវត្តន៍ ក្នុងរយៈពេល១(មួយ)ឆ្នាំយ៉ាងតិច លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាភិបាល ស.ហ.ក ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ១១.-**

លេខាធិការដ្ឋាន ស.ហ.ក ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៧

**ទេសាភិបាល**

**និងជាប្រធានក្រុមប្រឹក្សាភិបាល**

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

ស.ហ.ក

**ជា.ចាន់តូ**

កន្លែងទទួល

- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ដូចប្រការ ១១
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ឯកសារ-កាលប្បវត្តិ